32/5

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៤៦

ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២

សាលដីកា

លេខ : ២៨៤ (គ)

ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៣ ។

១-ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោកស្រី ជាចៅក្រម

៣-លោក ជាចៅក្រម

៤-លោក ជាចៅក្រម

៥-លោក ជាចៅក្រម

លោក

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

-ដើមចោទឈ្មោះ [redacted] ស្ងួន (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីលំនៅសព្វថ្ងៃភូមិត្រពាំងរុន ឃុំកន្ទ្រាមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

-ចុងចម្លើយឈ្មោះ [redacted] ធន់ ប្រពន្ធឈ្មោះ [redacted] ដានី (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីលំនៅសព្វថ្ងៃទីភូមិកន្ទ្រាមអក ឃុំកន្ទ្រាមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

<u>កម្មវត្ថុបណ្តឹង</u> ៖ ប្តឹងទាមទារប្រាក់ ។

**អំពីអង្គហេតុ និង ចំណុចវិវាទ :**

ក - <u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ</u>

តាមពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ របស់ដើមចោទឈ្មោះ [redacted] ស្ងួន [illegible] ចុងចម្លើយឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី បានពឹងខ្លួនឱ្យរកប្រាក់គេឱ្យ និងបានលេង តុងទីនជាមួយខ្លួន ហើយបានជំពាក់ប្រាក់ខ្លួនសរុបចំនួន ៨.១៥០.០០០ រៀល មិនព្រមសង។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

១៣១

Scanned with CamScanner

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ ឈ្មោះ [redacted] ធន់ បានមកធ្វើកិច្ចសន្យាទទួលស្គាល់ថា ពិតជាជំពាក់ខ្លួនចំនួន ៨.១៥០.០០០ រៀល ប្រាកដមែន តែក្រោយមកពេលខ្លួនទៅទារប្រាក់ពីប្ដីប្រពន្ធនេះស្រាប់តែប្រកែកមិនព្រមសង ហើយនិយាយថា ចង់ប្ដឹងឯណាប្ដឹងទៅ ទើបខ្លួនដាក់ពាក្យចូលមកតុលាការសុំប្ដឹងទាមទារប្រាក់ចំនួន ៨.១៥០.០០០ រៀល និងជំងឺចិត្ត ព្រមទាំងការខាតបង់ពេលវេលាចំនួន ២.០០០.០០០ រៀល។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៨ "ឆ" រ.វ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលស្គាល់ការទាមទាររបស់ដើមចោទ។

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី សងប្រាក់ជំពាក់ទៅដើមចោទចំនួន ៨.១៥០.០០០ រៀល (ប្រាំបីលានមួយសែនប្រាំម៉ឺនរៀល) និងសោហ៊ុយមធ្យោបាយ និងការខាតបងចំនួន ១.០០០.០០០ រៀល (មួយលានរៀល) នៅពេលសាលក្រមនេះចូលជាស្ថាពរ។ ករណីមិនព្រមសង ត្រូវរឹបអូសទ្រព្យសម្បត្តិ ដើម្បីលក់ឡៃឡុងយកប្រាក់សងទៅឲ្យដើមចោទ។

៣-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ចំពោះមុខដើមចោទ បើកសិទ្ធិទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ធន និងឈ្មោះ [redacted] ដានី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៨ "ឆ" រ.វ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រៃវែង គ្រប់ចំណុចសេចក្តីសំរេចទាំងមូល។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១០ "ឆ" រ.វ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-តម្កល់សាលក្រមលេខ ០៨ "ឆ" ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ទុកជាបានការទាំងមូល។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ ចំពោះមុខភាគី បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។



១៣៤

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ[redacted] ធន់ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១០ "ឆ" រ.វ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញសាលដីការរដ្ឋប្បវេណីលេខ ០២ ក្រIII (ណ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ច្រានពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ[redacted]ធន់ ចោលជាអសារបង់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១០ "ឆ" រ.វ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ឈ្មោះ [redacted]ធន់។

៤-សាលដីកានេះ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២។

-បានឃើញបណ្ដឹងសាទុក្ខលេខ ១៦៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ របស់ឈ្មោះ[redacted]ដានី ប្រពន្ធរបស់ឈ្មោះ [redacted] ធន់ ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ០២ ក្រIII (ណ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល។

ខ - <u>អំពីសេចក្ដីថ្លែងការណ៍របស់គូភាគី</u>

-អ្នកស្រី [redacted] ដានី ជាម្ចាស់បណ្ដឹងសាទុក្ខ បានធ្វើការអះអាងថា ៖

បានជាខ្លួនមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ដោយសារខ្លួនសុំសង ១៥.០០០ រៀល ក្នុង ១ ខែ តាមលទ្ធភាពដែលខ្លួនមាន។ លុយចងការចំនួន ១.៥០០.០០០ រៀល លុយតុងទីន ៤ ក្បាល ១ ក្បាល ១០ ម៉ឺនរៀល លុយតុងទីនដែលនៅជំពាក់មិនទាន់សងចំនួន ៥.៦០០.០០០ រៀល និងការប្រាក់ ១០% ក្នុង ១ ខែ។ កាលខ្លួនយកលុយពីគាត់ ខ្លួនបង់ការប្រាក់រហូតដល់ខែកក្កដា ឆ្នាំ២០១០។ ប្ដីខ្លួនទទួលស្គាល់ប្រាក់ចំនួន ៨.១៥០.០០០ រៀល។

<u>សំណូមពរ</u> : ខ្លួនសុំសំណូមពរតាមសារណាដែលខ្លួនសរសេរដាក់មក។

-លោក[redacted]សួន ជាចុងបណ្ដឹងសាទុក្ខ បានធ្វើការអះអាងថា ៖

លុយតុងទីនដែលនៅជំពាក់ខ្លួនចំនួន ៥.៦០០.០០០ រៀល និងលុយចងការ ១.៥០០.០០០ រៀល។ គាត់ឈប់បង់ការប្រាក់ពីខែវិច្ឆិកា ឆ្នាំ២០១០ ហើយលុយដែលគាត់ខ្ចីតាំងពីខែកក្កដា ឆ្នាំ២០១០។



១៣៩៦

៣២/២

<u>សំណូមពរ</u> : - ខ្លួនសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ។

- ខ្លួនសុំទាមទារជម្ងឺចិត្តចំនួន ៤ លានរៀល។

- ខ្លួនសុំបដិសេធចុងចម្លើយសុំសង ១ ខែ ១៥.០០០ រៀល។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-<u>យល់ឃើញថា</u>: បណ្តឹងសាទុក្ខលេខ ១៦៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ របស់ចុងចម្លើយ [redacted] ធន់ , [redacted] ដានី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-<u>យល់ឃើញថា</u>: ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ ដោយបង្គាប់អោយចុងចម្លើយសងប្រាក់ជំពាក់ចំនួន ៨.១៥០.០០០ រៀល ទៅអោយដើមចោទ ដោយផ្អែកទៅលើកិច្ចសន្យា ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ នោះ <u>ជាការមិនត្រឹមត្រូវទេ</u> ព្រោះថា ដើមចោទបានទទួលស្គាល់ថា ចុងចម្លើយបានខ្ចីចងការប្រាក់ពីខ្លួន គឺបានបង្ហាញថា មិនមែនជាកិច្ចសន្យាខ្ចី ដោយគ្មានការប្រាក់សុទ្ធសាធនោះទេ។ ម្យ៉ាងទៀត សាលាឧទ្ធរណ៍ក៏មិនបានពិចារណាអំពីការទទួលស្គាល់របស់គូភាគីដែលថា មានការខ្ចីប្រាក់ និងបង់ការប្រាក់ចាប់តាំងពីខែកក្កដា ឆ្នាំ២០០៧ មកផងដែរ។

-<u>យល់ឃើញថា</u>: សាលដីការដ្ឋប្បវេណីលេខ ០២ ក្រIII (ណ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមក មានលក្ខណៈខុសនឹងគតិច្បាប់។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ១៦៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ របស់ចុងចម្លើយ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ០២ ក្រIII (ណ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៤៦ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ របស់តុលាការកំពូល ត្រឡប់ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។



១៣៤៥

Scanned with CamScanner

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣។

-ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជំរះ

-លោកស្រី [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៣

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]